ក្រសួងមហាផ្ទៃ

# នីតិវិធី ដំណើរការ និងទម្រង់ នៃការពិគ្រោះយោបល់ និងការចូលរួមរបស់ប្រជាពលរដ្ឋ ជាមួយរដ្ឋបាលក្រុង ស្រុក និងយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន

បោះពុម្ពលើកទី៣
ខែធ្នូ ឆ្នាំ២០១១

# នីតិវិធី ដំណើរការ និងទម្រង់
# នៃការពិគ្រោះយោបល់ និងការចូលរួមរបស់
# ប្រជាពលរដ្ឋ ជាមួយរដ្ឋបាលក្រុង ស្រុក
# និងយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន

**បោះពុម្ពលើកទី៣**

**ខែធ្នូ ឆ្នាំ ២០១១**

# មាតិកា

**អារម្ភកថា**.......................................................................i

ជំពូក១: **ម៉ោងជួបរវាងរដ្ឋបាលក្រុង ស្រុក ខណ្ឌជាមួយប្រជាពលរដ្ឋ................១**

១. សេចក្តីផ្តើម ......................................................................៣

២. គោលបំណង ......................................................................៤

៣. ការរៀបចំ ......................................................................៤

៤. ទីកន្លែង ......................................................................៥

៥. ប្រតិទិននៃកិច្ចប្រជុំ......................................................................៥

៦. អ្នកចូលរួម ......................................................................៥

៧. ការផ្សព្វផ្សាយជូនដំណឹង......................................................................៦

៨. ការធ្វើកំណត់ហេតុប្រជុំ......................................................................៦

ជំពូក២: **វេទិកាពិគ្រោះយោបល់សាធារណៈប្រចាំឆមាស ..............................៩**

១. សេចក្តីផ្តើម ......................................................................១១

២. គោលបំណង ......................................................................១១

៣. ទីកន្លែង ......................................................................១២

៤. កាលបរិច្ឆេទ......................................................................១២

៥. របៀបវារៈ......................................................................១២

៦. អ្នកចូលរួម ......................................................................១៣

៧. ការរៀបចំលិខិតអញ្ជើញ ......................................................................១៤

៨. ការធ្វើកំណត់ហេតុប្រជុំ ......................................................១៤
ជំពូក៣: **យុទ្ធនាការផ្សព្វផ្សាយព័ត៌មាន ........................................១៥**
១. ការរៀបចំ..........................................................................១៧
២. ទីកន្លែង ..........................................................................១៨
៣. សកម្មភាពសំខាន់ៗ ..............................................................១៨
៤. ការរៀបចំរបាយការណ៍ ..........................................................២៤
ជំពូក៤: **វេទិកាប្រជាពលរដ្ឋប្រចាំឆ្នាំ ..................................................២៥**
**អារម្ភកថា ..........................................................................២៧**
១. សេចក្តីផ្តើម .......................................................................២៩
២. នីតិវិធី និងដំណើរការនៃការរៀបចំ ............................................៣១
២.១ អ្វីទៅជាវេទិកាប្រជាពលរដ្ឋប្រចាំឆ្នាំ? ..................................៣១
២.២ គោលបំណង ...........................................................៣១
២.៣ ការកំណត់របៀបវារៈ កាលបរិច្ឆេទ ទីកន្លែង......................៣២
២.៤ សមាសភាពចូលរួម និងវាគ្មិន .......................................៣៣
២.៥ នីតិវិធីនៃការចូលរួម .................................................៣៣
២.៦ ឧបករណ៍ សម្ភារ និងឯកសារផ្សព្វផ្សាយ ...............................៣៤
២.៧ ការត្រៀមលក្ខណៈថែវទន្យ .............................................៣៥
២.៨ របាយការណ៍ ............................................................៣៥

# អារម្ភកថា

ការពិគ្រោះយោបល់ និងការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាធាតុដ៏សំខាន់មួយក្នុងចំណោមធាតុសំខាន់៧ដទៃទៀតនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងការផ្តល់សេវាសាធារណៈឱ្យកាន់តែប្រសើរឡើងជូនប្រជាពលរដ្ឋ ស្របតាមគោលការណ៍អភិបាលកិច្ចល្អដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

ធាតុដ៏សំខាន់ខាងលើនេះ ត្រូវបានកំណត់នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា ។

ក្នុងការឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងគោលដៅដើម្បីពង្រឹងប្រសិទ្ធភាព គុណភាព តម្លាភាព និងឆ្លើយតប តាមតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ក្នុងការផ្តល់សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋ និងដើម្បីបង្កលក្ខណៈឱ្យកាន់តែមានភាពស្និទ្ធស្នាល ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវការចូលរួមតាមបែបប្រជាធិបតេយ្យនៅមូលដ្ឋាន រាជរដ្ឋាភិបាលបានសម្រេចឱ្យបង្កើតឡើងនូវការិយាល័យច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ ។ ដើម្បីធានាប្រសិទ្ធភាពនៃដំណើរការរបស់ការិយាល័យច្រកចេញចូលតែមួយ ក្រុង ស្រុក ខណ្ឌ

គោលដៅនីមួយៗ ត្រូវរៀបចំឱ្យមានទម្រង់នៃការពិគ្រោះយោបល់ និងការចូលរួមនានារបស់ប្រជាពលរដ្ឋ ដូចជាៈ **វេទិកាប្រជាពលរដ្ឋប្រចាំឆ្នាំ វេទិកាសាធារណៈប្រចាំឆមាស ម៉ោងជួបរវាងប្រជាពលរដ្ឋ និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន** ។ល ។

**សៀវភៅណែនាំស្តីពីនីតិវិធី និងដំណើរការនៃការរៀបចំម៉ោងជួបរវាងគណៈអភិបាលក្រុង ស្រុក ខណ្ឌ ជាមួយប្រជាពលរដ្ឋ វេទិកាសាធារណៈប្រចាំឆមាសនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន** ជាឯកសារសម្រាប់ណែនាំដល់ក្រុមប្រឹក្សា គណៈអភិបាលក្រុង ស្រុក ខណ្ឌ មន្ត្រីរដ្ឋបាលក្រុង ស្រុក ខណ្ឌ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ក្នុងការរៀបចំវេទិកា និងកិច្ចប្រជុំខាងលើនេះ ។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មានសង្ឃឹមយ៉ាងមុតមាំថា ក្រុមប្រឹក្សា គណៈអភិបាល មន្ត្រី បុគ្គលិក និងអ្នកពាក់ព័ន្ធនានា នឹងអនុវត្តតាមសៀវភៅណែនាំនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ, ថ្ងៃទី ...១៧... ខែ មិនា. ឆ្នាំ ២០១០

**រដ្ឋលេខាធិការ និងជា**

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.**

សក់ សេដ្ឋា

ការិយាល័យច្រកចេញចូលតែមួយ

សេវាសាធារណៈ តម្លាភាព

ONE WINDOW SERVICE OFFICE

# <u>ជំពូក១</u>

# ម៉ោងជួបរវាងរដ្ឋបាល

# ក្រុង ស្រុក ខណ្ឌជាមួយប្រជាពលរដ្ឋ

# ម៉ោងជួបរវាង
# រដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាមួយប្រជាពលរដ្ឋ

## ១.សេចក្តីផ្តើម

ការពិគ្រោះយោបល់ និងការចូលរួម គឺជាធាតុដ៏សំខាន់ និងចាំបាច់មួយ នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។ មានវិធីសាស្ត្រ និងទម្រង់ជាច្រើន នៃការពិគ្រោះយោបល់ និងការចូលរួម ដែលត្រូវរៀបចំឡើងទាំងនៅស្ថាប័នរដ្ឋ (ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) និងស្ថាប័នមិនមែនរដ្ឋ។

ការពិគ្រោះយោបល់ និងការចូលរួម គឺជាចលករមួយដែលជំរុញឱ្យមានការអភិវឌ្ឍមួយប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងការឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅតាមមូលដ្ឋាននីមួយៗ។

ម៉ោងជួបរវាងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាមួយប្រជាពលរដ្ឋប្រចាំខែ និងវេទិកាសាធារណៈប្រចាំឆមាសរវាងរដ្ឋបាលក្រុង ស្រុក ខណ្ឌជាមួយតំណាងប្រជាពលរដ្ឋ និងតំណាងពាណិជ្ជករ ដែលមានទីតាំងនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុង ស្រុក ខណ្ឌគោលដៅ គឺជាទម្រង់មួយដ៏មានប្រសិទ្ធភាពក្នុងការប្រមូលមតិយោបល់ចូលរួមរបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា ក្នុងការធ្វើសេចក្តីសម្រេចចិត្តនានា ដែលពាក់ព័ន្ធនឹងកិច្ចការអភិវឌ្ឍ និងការផ្តល់សេវាសាធារណៈ របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ក្នុងគោលបំណងដើម្បីបង្កើនការចូលរួម និងការស្វែងយល់អំពីចំណេះដឹង និងព័ត៌មាននានា ជាពិសេសដើម្បីបង្កើនទំនាក់ទំនងកាន់តែជិតស្និទ្ធរវាងមន្ត្រីរាជការ បុគ្គលិករដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាមួយប្រជាពលរដ្ឋ ម៉ោងជួបរវាងរដ្ឋបាលក្រុង ស្រុក ខណ្ឌជាមួយប្រជាពលរដ្ឋ នឹងត្រូវរៀបចំឡើងប្រចាំខែនៅថ្នាក់ក្រុង ស្រុក ខណ្ឌ គោលដៅនៃការិយាល័យច្រកចេញចូលតែមួយ ។

## ២.គោលបំណង

- ផ្តល់ឱកាសជូនប្រជាពលរដ្ឋ ដើម្បីលើកឡើងនូវសំនួរ សំណើ សំណូមពរ និងការទិតៀននានាជុំវិញបញ្ហាដែលពាក់ព័ន្ធនឹងការិយាល័យច្រកចេញចូលតែមួយ ការិយាល័យប្រជាពលរដ្ឋ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រម ទាំងបញ្ហាផ្សេងៗទៀត
- ប្រមូលនូវគំនិត មតិយោបល់ និងការទិតៀននានា ដើម្បីធ្វើជាមូលដ្ឋានក្នុងការកែលម្អដោះស្រាយ និងពង្រឹងការអនុវត្តការិយាល័យច្រកចេញចូលតែមួយ ការិយាល័យប្រជាពលរដ្ឋ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឱ្យបានទាន់ពេលវេលា ។

## ៣.ការរៀបចំ

អភិបាលក្រុង ស្រុក ខណ្ឌគោលដៅនីមួយៗ ដែលមានការិយាល័យច្រកចេញ ចូលតែមួយ ត្រូវចាត់តាំងមន្ត្រី ដែលទទួលបន្ទុកការងាររដ្ឋបាល ឬមន្ត្រីពាក់ព័ន្ធមួយ(០១)រូប ឱ្យទទួលខុសត្រូវ និងសម្របសម្រួលការរៀបចំម៉ោងជួបរវាងរដ្ឋបាលក្រុង ស្រុក ខណ្ឌជាមួយប្រជាពលរដ្ឋប្រចាំខែ ។

ម៉ោងជួបនេះ ត្រូវមានការចូលរួមដោយផ្ទាល់ពីអភិបាលក្រុង ស្រុក ខណ្ឌ ឬ/និងអភិបាលរងក្រុង ស្រុក ខណ្ឌដែលពាក់ព័ន្ធ( ក្នុងករណីដែលអភិបាលជាប់បំពេញភារកិច្ចចាំបាច់ណាមួយ) ព្រមទាំងមន្ត្រីពាក់ព័ន្ធផ្សេងៗទៀត។

## ៤.ទីកន្លែង

ម៉ោងជួបរវាងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាមួយប្រជាពលរដ្ឋប្រចាំខែត្រូវរៀបចំឡើងនៅសាលាក្រុង ស្រុក ខណ្ឌគោលដៅនោះ ឬនៅកន្លែងណាមួយសមស្របតាមការកំណត់របស់អភិបាលក្រុង ស្រុក ខណ្ឌ។

## ៥.ប្រតិទិននៃកិច្ចប្រជុំ

នៅរៀងរាល់ដើមឆ្នាំនីមួយៗ អភិបាលក្រុង ស្រុក ខណ្ឌគោលដៅនីមួយៗ ត្រូវរៀបចំប្រតិទិននៃម៉ោងជួបរវាងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាមួយប្រជាពលរដ្ឋជារៀងរាល់ខែ សម្រាប់រយៈពេល១២ខែ។ ប្រតិទិននេះ ត្រូវកំណត់យកថ្ងៃណាមួយនៃខែនីមួយៗ និងពេលវេលាច្បាស់លាស់សម្រាប់ម៉ោងជួបនេះ។

ម៉ោងជួបនេះអាចប្រព្រឹត្តិទៅក្នុងរយៈពេលកន្លះថ្ងៃ( មួយព្រឹក ឬមួយរសៀល) ឬមួយថ្ងៃពេញ តាមការកំណត់ជាក់ស្តែងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

## ៦.អ្នកចូលរួម

- អភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌ
- ប្រធានការិយាល័យច្រកចេញចូលតែមួយ
- ប្រធានការិយាល័យប្រជាពលរដ្ឋ
- ប្រជាពលរដ្ឋទាំងពីរភេទ

## ៧.ការផ្សព្វផ្សាយជូនដំណឹង

ក្រោយពេលរៀបចំ និងកំណត់ច្បាស់លាស់ហើយនូវទីកន្លែង និងប្រតិទិននៃ ម៉ោងជួបតាមខែនីមួយៗរួចហើយ អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់ឱ្យធ្វើការផ្សព្វផ្សាយ ជូនដំណឹងជាសាធារណៈជូនដល់ប្រជាពលរដ្ឋទាំងអស់នៅក្នុងក្រុង ស្រុក ខណ្ឌគោលដៅនោះ ។

ការផ្សព្វផ្សាយជូនដំណឹងនេះ ត្រូវធ្វើឡើងតាមរយៈ

- ការបិទផ្សាយនៅលើក្តារព័ត៌មានសាធារណៈ នៅមុខសាលាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ឬតាមទីកន្លែងសាធារណៈផ្សេងៗទៀត ។
- ការបោះពុម្ពព័ត៌មាននៅលើខិតប័ណ្ណ ប័ណ្ណផ្សព្វផ្សាយព័ត៌មាន និងប័ណ្ណបិទផ្សាយ
- វេទិកាប្រជាពលរដ្ឋ ឬវេទិកាសាធារណៈនានារបស់ក្រុង ស្រុក ខណ្ឌ
- វិទ្យុ ទូរទស្សន៍តាមកម្មវិធីសំណួរ-ចម្លើយ
- មធ្យោបាយផ្សេងៗទៀត

ក្នុងករណីដែលមានការផ្លាស់ប្តូរទីកន្លែង ឬកាលបរិច្ឆេទនៃម៉ោងជួបរវាងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាមួយប្រជាពលរដ្ឋ អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់ឱ្យធ្វើការផ្សព្វផ្សាយជូនដំណឹងជាបន្ទាន់ភ្លាមដល់ប្រជាពលរដ្ឋឱ្យបានយ៉ាងតិចមួយ(០១)សប្តាហ៍មុនថ្ងៃណាត់ជួប ។

## ៧.ការធ្វើកំណត់ហេតុប្រជុំ

មន្ត្រីដែលទទួលខុសត្រូវរៀបចំ និងសម្របសម្រួលម៉ោងជួបនេះត្រូវរៀបចំកំណត់ហេតុ និងបញ្ជីវត្តមានសឱ្យបានច្បាស់លាស់ ដើម្បីតំកល់ទុកជាឯកសារ

និងចម្លងជូនក្រុមប្រឹក្សា និងក្រុមគាំទ្រថ្នាក់ក្រុង ស្រុក ខណ្ឌ នៃក្រសួងមហាផ្ទៃ ដើម្បីជូនជ្រាបជាព័ត៌មាន។

# ជំពូក២

# វេទិកាពិគ្រោះយោបល់សាធារណៈ

# ប្រចាំឆមាស

# វេទិកាពិគ្រោះយោបល់សាធារណៈប្រចាំឆមាស

## ១.សេចក្តីផ្តើម

ដើម្បីធ្វើឱ្យកាន់តែមាននិរន្តរភាព និងទទួលបាននូវព័ត៌មានត្រឡប់ ដែលជាមូលដ្ឋានដ៏សំខាន់ដើម្បីធ្វើការកែលម្អការផ្តល់សេវាសាធារណៈតាមការិយាល័យច្រកចេញចូលតែមួយ ការសម្របសម្រួលដោះស្រាយវិវាទ តាមរយៈប្រធានការិយាល័យប្រជាពលរដ្ឋ និងការកែលម្អដំណើរការរដ្ឋបាល ក្រុង ស្រុក ខណ្ឌ អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់តាំងមន្ត្រីទទួលបន្ទុកការងាររដ្ឋបាល ឬមន្ត្រីពាក់ព័ន្ធចំនួនមួយ(០១)រូប ដើម្បីរៀបចំ និងសម្របសម្រួលកិច្ចប្រជុំពិគ្រោះយោបល់រវាងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាមួយតំណាងប្រជាពលរដ្ឋ និងតំណាងពាណិជ្ជករ ដែលកំណត់ហៅថា "វេទិកាសាធារណៈប្រចាំឆមាស" ។

កិច្ចប្រជុំនេះ ត្រូវរៀបចំឡើងដោយលក្ខណៈសាមញ្ញ (មិនផ្លូវការ) ។

## ២.គោលបំណង

- ផ្តល់ឱកាសដល់តំណាងប្រជាពលរដ្ឋ និងតំណាងពាណិជ្ជករ បានសំដែងនូវមតិយោបល់ និងអនុសាសន៍ជុំវិញបញ្ហានានា ដែលពាក់ព័ន្ធនឹងកិច្ចដំណើរការរបស់ការិយាល័យច្រកចេញចូលតែមួយ ការិយាល័យប្រជាពលរដ្ឋ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ប្រមូលមតិយោបល់ត្រឡប់ និងអនុសាសន៍ទាំងឡាយ ដើម្បីលើកយោបល់

ជូនក្រុមគាំទ្រថ្នាក់ក្រុង ស្រុក ខណ្ឌ នៃក្រសួងមហាផ្ទៃ ដើម្បីរៀបចំដាក់ជូនក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួង និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីពិនិត្យ និងធ្វើការកែលម្អ

- បង្កើនទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាមួយប្រជាពលរដ្ឋ និងពាណិជ្ជករ ។

## ៣.ទីកន្លែង

វេទិកាសាធារណៈប្រចាំឆមាសត្រូវរៀបចំឡើងនៅសាលាក្រុង ស្រុក ខណ្ឌ គោលដៅនោះ ឬនៅកន្លែងណាមួយ សមស្របតាមការកំណត់របស់អភិបាលក្រុង ស្រុក ខណ្ឌ ។

## ៤.កាលបរិច្ឆេទ

នៅរៀងរាល់ខែមិថុនា នៃឆ្នាំនីមួយៗ អភិបាលក្រុង ស្រុក ខណ្ឌ គោលដៅនីមួយៗ ត្រូវចាត់ឱ្យមានការរៀបចំវេទិកានេះឡើង ។

វេទិកានេះអាចប្រព្រឹត្តិទៅក្នុងរយៈពេលកន្លះថ្ងៃ (មួយព្រឹក ឬមួយរសៀល) ឬមួយថ្ងៃពេញ តាមការកំណត់ជាក់ស្តែងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ។

## ៥.របៀបវារៈ

អភិបាលក្រុង ស្រុក ខណ្ឌគោលដៅនីមួយៗ ត្រូវចាត់ឱ្យមន្ត្រីទទួលខុសត្រូវសម្របសម្រួល រៀបចំសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំនេះ ។

របៀបវារៈនៃកិច្ចប្រជុំអាចលើកឡើងអំពីៈ

១-មតិចំណាប់អារម្មណ៍របស់អភិបាលក្រុង ស្រុក ខណ្ឌ

២-មតិយោបល់ និងអនុសាសន៍នានា ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងអាកប្បកិរិយារបស់មន្ត្រី បុគ្គលិក នីតិវិធី ទម្រង់បែបបទនៃការផ្តល់សេវា និងការពង្រីកសមត្ថកិច្ច( ប្រភេទ ទំហំ មុខងារ) របស់តំណាងប្រជាពលរដ្ឋ និងតំណាងពាណិជ្ជករ

៣-ការពិភាក្សា ការពិគ្រោះយោបល់ និងការឆ្លើយតបនានា របស់អភិបាលក្រុង ស្រុក ខណ្ឌ

៤-បញ្ហាផ្សេងៗទៀត

## ៦.អ្នកចូលរួម

- អភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌ
- ប្រធានការិយាល័យច្រកចេញចូលតែមួយ
- ប្រធានការិយាល័យប្រជាពលរដ្ឋ
- តំណាងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- នាយករដ្ឋបាល ឬប្រធានការិយាល័យពាក់ព័ន្ធ
- តំណាងប្រជាពលរដ្ឋ
- តំណាងពាណិជ្ជករ
- អ្នកពាក់ព័ន្ធផ្សេងៗទៀតតាមការចាំបាច់

**<u>ចំណាំ:</u>** អ្នកចូលរួមត្រូវមានស្ត្រីយ៉ាងតិច ៣០ភាគរយចូលរួម។

# ៧.ការរៀបចំលិខិតអញ្ជើញ

**ចំណាំ**

- តំណាងប្រជាពលរដ្ឋ ត្រូវជ្រើសរើសមកពីគ្រប់ឃុំ សង្កាត់ទាំងអស់ នៃក្រុង ស្រុក ខណ្ឌគោលដៅនោះ យ៉ាងតិចពីរ(០២)រូបក្នុងឃុំ សង្កាត់នីមួយៗ។ តំណាងប្រជាពលរដ្ឋនេះ អាចជាក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេភូមិ ។
- តំណាងពាណិជ្ជករ ត្រូវជ្រើសរើសតំណាងតាមប្រភេទមុខរបរនីមួយៗ ដែលបានទទួលសេវាពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈការិយាល័យច្រកចេញចូលតែមួយ ។

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់ឱ្យមន្ត្រីទទួលខុសត្រូវ និងសម្របសម្រួលវេទិកានេះ រៀបចំលិខិតអញ្ជើញអ្នកចូលរួមដូចមានកំណត់ខាងលើនេះ ដើម្បីចូលរួមក្នុងវេទិកា។

លិខិតអញ្ជើញ ត្រូវចែកជូនដល់អ្នកចូលរួមទាំងអស់ ឱ្យបានមុនយ៉ាងតិចពីរ(០២)ថ្ងៃ មុនថ្ងៃចាប់ផ្តើមវេទិកា។

# ៨.ការធ្វើកំណត់ហេតុប្រជុំ

មន្ត្រីដែលទទួលខុសត្រូវសម្របសម្រួលវេទិកានេះ ត្រូវរៀបចំកំណត់ហេតុ និងបញ្ជីវត្តមានឱ្យបានច្បាស់លាស់ ដើម្បីតំកល់ទុកជាឯកសារ និងចម្លងជូនក្រុមប្រឹក្សា និងក្រុមគាំទ្រថ្នាក់ក្រុង ស្រុក ខណ្ឌក្រសួងមហាផ្ទៃ ដើម្បីជូនជ្រាបជាព័ត៌មាន។

# ជំពូក៣

# យុទ្ធនាការផ្សព្វផ្សាយព័ត៌មាន

# យុទ្ធនាការផ្សព្វផ្សាយព័ត៌មាន

## ១.ការរៀបចំ

បន្ទាប់ពីការបើកការិយាល័យច្រកចេញចូលតែមួយភ្លាម យុទ្ធនាការផ្សព្វផ្សាយព័ត៌មានពេញមួយសប្តាហ៍ នឹងត្រូវបានរៀបចំឡើង ដើម្បីជូនព័ត៌មានទៅប្រជាពលរដ្ឋអំពីការិយាល័យថ្មីនេះ។ ចំពោះការងារនេះ រដ្ឋបាលក្រុង ស្រុក ត្រូវបានផ្តល់ជូននូវខិតប័ណ្ណ ប័ណ្ណផ្សព្វផ្សាយព័ត៌មាន និងប័ណ្ណបិទផ្សាយ។

ស្របពេលជាមួយគ្នានេះដែរ ក្នុងកិច្ចសហប្រតិបត្តិការជាមួយវិទ្យុជាតិ កម្ពុជា និងស្ថានីយផ្សព្វផ្សាយសំលេងផ្សេងៗទៀត កម្មវិធីសំនួរ-ចំលើយ នឹងត្រូវបានរៀបចំឡើងតាមវិទ្យុ ដែលអភិបាលក្រុង ស្រុក ខណ្ឌ ប្រធាន ការិយាល័យច្រកចេញចូលតែមួយ និងប្រធានការិយាល័យប្រជាពលរដ្ឋអាចឆ្លើយ នូវសំនួរទាំងឡាយរបស់ប្រជាពលរដ្ឋ។

យុទ្ធនាការផ្សព្វផ្សាយព័ត៌មាននេះ នឹងត្រូវរៀបចំឡើងយ៉ាងតិចមួយដងក្នុងមួយឆ្នាំ នៅក្រុង ស្រុក ខណ្ឌគោលដៅនីមួយៗ រួមមានទាំងការ ផ្សព្វផ្សាយព័ត៌មានតាមសាលារៀន ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្ថាប័នក្នុងក្រុង ស្រុក ខណ្ឌ ផ្សេងទៀត ។

នៅគ្រប់ទីកន្លែងនៃយុទ្ធនាការផ្សព្វផ្សាយព័ត៌មានសម្រាប់ការិយាល័យច្រកចេញចូលតែមួយ ក៏នឹងត្រូវបានប្រើប្រាស់សំរាប់ធ្វើឱ្យប្រជាពលរដ្ឋបាន

ជ្រាបព័ត៌មានយ៉ាងទូលំទូលាយអំពីការិយាល័យប្រជាពលរដ្ឋផងដែរ ។ បន្ថែមពីលើនេះទៀត បើទោះជាយ៉ាងណាក៏ដោយ ក៏ត្រូវមានការខិតខំប្រឹងប្រែងផ្សព្វផ្សាយព័ត៌មានបន្ថែមទៀត ដូចជាកម្មវិធីសំនួរ-ចំលើយតាមវិទ្យុជាមួយនឹងប្រធានការិយាល័យប្រជាពលរដ្ឋ ដំណើរទស្សនកិច្ចរបស់ប្រធានការិយាល័យប្រជាពលរដ្ឋទៅកាន់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកទាំងអស់ ។

ការផ្សព្វផ្សាយប័ណ្ណព័ត៌មានដោយមានការពិពណ៌នាយ៉ាងសង្ខេបអំពីការទទួលខុសត្រូវរបស់ការិយាល័យប្រជាពលរដ្ឋ និងក្រដាសបិទផ្សាយដោយមានលេខទូរសព្ទផងដែរ ។

## ២.ទីកន្លែង

- នៅទីសាធារណៈ ឬនៅសាលាក្រុង ស្រុក ខណ្ឌគោលដៅ
- នៅតាមទីប្រជុំជន

## ៣.សកម្មភាពសំខាន់ៗ

ក្នុងការរៀបចំយុទ្ធនាការផ្សព្វផ្សាយព័ត៌មាននេះ អភិបាលក្រុង ស្រុក ខណ្ឌគោលដៅនីមួយៗ ត្រូវរៀបចំនូវសកម្មភាពសំខាន់ៗដូចខាងក្រោម :

❶ ការរៀបចំអង្គប្រជុំបើកយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន

❷ ការចាក់ផ្សាយព័ត៌មានតាមផ្លូវ និងទីសាធារណៈនានាក្នុងក្រុង ស្រុក ខណ្ឌគោលដៅនីមួយៗ

❸ កម្មវិធីសន្ទនាមតិតាមវិទ្យុ

## សកម្មភាពទី❶: ការរៀបចំកិច្ចប្រជុំបើកយុទ្ធនាការផ្សព្វផ្សាយ:

### ☛ សមាសភាពចូលរួម

នៅថ្ងៃបើកយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន អភិបាលក្រុង ស្រុក ខណ្ឌ គោលដៅត្រូវរៀបចំការប្រជុំមួយដែលមានសមាសភាពចូលរួមដូចខាងក្រោមៈ

- អភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌ
- សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- មន្ត្រីរាជការស៊ីវិលសាលាក្រុង ស្រុក ខណ្ឌ
- ប្រធានការិយាល័យប្រជាពលរដ្ឋ
- ប្រធាន អនុប្រធាន និងមន្ត្រីការិយាល័យជំនាញពាក់ព័ន្ធនានា
- តំណាងមន្ទីរ អង្គភាពពាក់ព័ន្ធ
- ក្រុមប្រឹក្សាឃុំ សង្កាត់
- ប្រជាពលរដ្ឋ
- សិស្ស និស្សិត
- តំណាងអង្គការមិនមែនរដ្ឋាភិបាលនានា
- អ្នកពាក់ព័ន្ធផ្សេងៗទៀត

**<u>ចំណាំៈ</u>** អ្នកចូលរួមត្រូវមានស្ត្រីយ៉ាងតិច ៣០ភាគរយចូលរួម។

### ☛ វិធីសាស្ត្រ:

- បន្ទាប់មកត្រូវរៀបចំក្បួនដង្ហែយុទ្ធនាការផ្សព្វផ្សាយទៅតាមផ្លូវសាធារណៈ ទីសាធារណៈនានានៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនោះ។

ក្នុងក្បួនដង្ហែយុទ្ធនាការផ្សព្វផ្សាយនេះ ត្រូវចាត់ឱ្យមានការផ្សព្វផ្សាយព័ត៌មាននានាដែលពាក់ព័ន្ធនឹងតួនាទីភារកិច្ចរបស់ការិយាល័យច្រកចេញចូលតែមួយ តួនាទីភារកិច្ចនៃការិយាល័យប្រជាពលរដ្ឋ អំពីសេវាសាធារណៈនានាដែលត្រូវផ្ដល់ជូនប្រជាពលរដ្ឋតាមការិយាល័យច្រកចេញចូលតែមួយ ។ ការផ្សព្វផ្សាយនេះ អាចធ្វើតាមការអានព័ត៌មានដោយផ្ទាល់មាត់ផង និងតាមការចាក់ផ្សាយនូវខ្សែអាត់សម្លេងផង ។

- ដើម្បីឱ្យការផ្សព្វផ្សាយនេះ មានការចាប់អារម្មពីសំណាក់ប្រជាពលរដ្ឋចាំបាច់ត្រូវរៀបចំឱ្យមានការចាក់ផ្សាយបទចំរៀងនានាដែលពាក់ព័ន្ធអត្ថន័យនៃការិយាល័យច្រកចេញចូលតែមួយ ឬឆៃយាំ និងការស្រែកជ័យឃោសនានានារបស់អ្នកចូលរួម ។
- ក្នុងដំណើរក្បួនផ្សព្វផ្សាយនេះ គណៈអភិបាលត្រូវមានចំណាប់អារម្មណ៍ខ្លីៗនៅទីប្រជុំជននានា ពាក់ព័ន្ធនឹងគោលបំណងខាងលើ ។

## ☛ ខ្លឹមសារៈ

ខ្លឹមសារនៃការផ្សព្វផ្សាយមានដូចខាងក្រោម ៖

- តួនាទី ភារកិច្ចរបស់ការិយាល័យច្រកចេញចូលតែមួយ
- តួនាទី ភារកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋ
- បណ្ដាសេវាសាធារណៈនានា ដែលត្រូវផ្ដល់ជូនប្រជាពលរដ្ឋតាមរយៈការិយាល័យច្រកចេញចូលតែមួយ
- ខ្លឹមសារផ្សេងៗទៀតតាមការជាក់ស្ដែងរបស់ក្រុង ស្រុក ខណ្ឌគោលដៅនីមួយៗ

☛ **សម្ភារៈ**

- រោង និងកៅអីសម្រាប់កិច្ចប្រជុំបើកយុទ្ធនាការផ្សព្វផ្សាយ
- មធ្យោបាយនានាសម្រាប់ដង្ហែក្បួនយុទ្ធនាការផ្សព្វផ្សាយរួមមាន យានយន្ត ម៉ូតូ កង់..... ។ល។
- ឧបករណ៍បំពងសំឡេង
- ខ្សែអាត់សម្លេង
- បដាពាក្យស្លោក
- ខិតប័ណ្ណ ប័ណ្ណផ្សព្វផ្សាយព័ត៌មាន និងប័ណ្ណបិទផ្សាយ
- ឯកសណ្ឋាន( អាវ មួក)
- ទង់ជាតិ និងទង់បោះពុម្ពមានរូបសញ្ញាការិយាល័យច្រកចេញចូលតែមួយ

**ខ្លឹមសារបដា:**

- ជយោ! ព្រះរាជាណាចក្រកម្ពុជា
- ជយោ! រាជរដ្ឋាភិបាលកម្ពុជា
- រដ្ឋបាលក្រុង ស្រុក ផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ
- រដ្ឋបាលក្រុង ស្រុក បម្រើប្រជាពលរដ្ឋអោយកាន់តែល្អប្រសើរ
- រដ្ឋបាលក្រុង ស្រុកផ្តល់សេវាសាធារណៈប្រកបដោយគុណភាពល្អ តម្លៃថោក រយៈពេលខ្លី សាមញ្ញ អាចជឿទុកចិត្តបាន និងឆ្លើយតបទាន់ពេលវេលា
- ជយោ! គោលនយោបាយកំណែទម្រង់រដ្ឋបាលរបស់រាជរដ្ឋាភិបាល
- ការិយាល័យច្រកចេញចូលតែមួយ ស្ថិតនៅក្នុងសាលាក្រុង ស្រុក........

- ការិយាល័យច្រកចេញចូលតែមួយ ជាកន្លែងផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ
- កែលម្អការផ្តល់សេវាសាធារណៈ កាត់បន្ថយអំពើពុករលួយ និងបង្កើតការជឿទុកចិត្ត ពីប្រជាពលរដ្ឋលើរដ្ឋបាលក្រុង ស្រុក។
- លើកកំពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការផ្តល់មតិយោបល់ និងការរិះគន់ស្ថាបនា ដើម្បីកែលម្អការផ្តល់សេវាជូនប្រជាពលរដ្ឋ
- ការិយាល័យច្រកចេញចូលតែមួយ ជាកន្លែងប្រមូលផ្តុំសេវាកម្ម និងនីតិវិធីរដ្ឋបាលមួយចំនួននៅកន្លែងតែមួយ
- ការិយាល័យច្រកចេញចូលតែមួយ ជាកន្លែងដែលអតិថិជនមកទទួលទម្រង់បែបបទ ឬទទួលព័ត៌មានស្តីពីការផ្តល់សេវាសាធារណៈផ្សេងៗ
- ការិយាល័យច្រកចេញចូលតែមួយ ជាកន្លែងផ្តល់លទ្ធផលសម្រេចជាផ្លូវការដល់អតិថិជន
- ការិយាល័យប្រជាពលរដ្ឋ ទទួលពាក្យបណ្តឹងតវ៉ា និងសម្រុះសម្រួលដោះស្រាយពាក្យបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋ
- ប្រធានការិយាល័យប្រជាពលរដ្ឋ ជាតំណាងរបស់ប្រជាពលរដ្ឋក្នុងការសម្រុះសម្រួលដោះស្រាយពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ ជាមួយរដ្ឋបាលក្រុង ស្រុក....
- ការិយាល័យប្រជាពលរដ្ឋ ជាយន្តការប្រឆាំងនឹងអំពើពុករលួយរបស់មន្ត្រីរាជការ

- ការិយាល័យប្រជាពលរដ្ឋ ការពារ និងជួយប្រជាពលរដ្ឋ

ក្រៅពីខ្លឹមសារដែលបានកំណត់ខាងលើ ក្រុង ស្រុក ខណ្ឌគោលដៅ អាចបង្កើតខ្លឹមសារផ្សេងៗទៀតដែលពាក់ព័ន្ធនឹងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬការិយាល័យថ្មីទាំងពីរនេះ។

**សកម្មភាពទី❷: ការចាក់ផ្សាយព័ត៌មានតាមផ្លូវ និងទីសាធារណៈនានាក្នុង ក្រុង ស្រុក ខណ្ឌគោលដៅនីមួយៗ**

ពាក់ព័ន្ធនឹងសកម្មភាពនេះ ក្រុង ស្រុក ខណ្ឌគោលដៅនីមួយៗ បន្ទាប់ពីថ្ងៃបើកយុទ្ធនាការផ្សព្វផ្សាយព័ត៌មានមក ត្រូវរៀបចំឱ្យមានយាន្តយន្ត ឬត្រីចក្រយាន្តយន្ត ឬមធ្យោបាយផ្សេងទៀតដើម្បីធ្វើការចាក់ផ្សាយនូវខ្លឹមសារ និងព័ត៌មាននានា ដែលពាក់ព័ន្ធនឹងការិយាល័យច្រកចេញចូលតែមួយ ការិយាល័យប្រជាពលរដ្ឋ និងព័ត៌មានអំពីសេវាកម្មនានា ជាប្រចាំនៅតាមផ្លូវសាធារណៈ ឬទីប្រជុំជន ឬទីសាធារណៈនានាក្នុងដែនសមត្ថកិច្ចរបស់ក្រុង ស្រុក ខណ្ឌគោលដៅនោះ ក្នុងរយៈពេលមួយសប្តាហ៍ពេញក្រោយពីថ្ងៃប្រកាសបើកជាផ្លូវការនៃការិយាល័យច្រកចេញចូលតែមួយ។

**សកម្មភាពទី❸: កម្មវិធីសន្ទនាមតិតាមវិទ្យុ**

ក្នុងអំឡុងពេលនៃយុទ្ធនាការផ្សព្វផ្សាយព័ត៌មាននេះ អភិបាល ឬអភិបាលរង ទទួលបន្ទុកការិយាល័យច្រកចេញចូលតែមួយ ប្រធានការិយាល័យច្រកចេញចូលតែមួយ និងប្រធានការិយាល័យប្រជាពលរដ្ឋ ត្រូវសហការទំនាក់ទំនងជាមួយវិទ្យុក្នុងមូលដ្ឋាន ដើម្បីរៀបចំកម្មវិធីសន្ទនាមតិដោយអភិបាល ឬអភិបាលរង ប្រធាន

ការិយាល័យច្រកចេញចូលតែមួយ ប្រធានការិយាល័យប្រជាពលរដ្ឋ ត្រូវចូលរួមជាវាគ្មិនក្នុងកម្មវិធីនេះ។

## ៤.ការរៀបចំរបាយការណ៍

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់ឱ្យរៀបចំរបាយការណ៍ស្តីពីការរៀបចំយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន ដើម្បីតំកល់ទុកជាឯកសារ និងចម្លងជូនក្រុមប្រឹក្សា និងក្រុមគាំទ្រថ្នាក់ក្រុង ស្រុក ខណ្ឌក្រសួងមហាផ្ទៃ ដើម្បីជូនជ្រាបជាព័ត៌មាន។

# ជំពូក៤

# វេទិកាប្រជាពលរដ្ឋប្រចាំឆ្នាំ

# អារម្ភកថា

ការពិគ្រោះយោបល់ និងការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាធាតុដ៏សំខាន់មួយ ក្នុងចំណោមធាតុសំខាន់៧ដទៃទៀតនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងការផ្តល់សេវាសាធារណៈឱ្យកាន់តែប្រសើរឡើងជូនប្រជាពលរដ្ឋ ស្របតាមគោលការណ៍អភិបាលកិច្ចល្អដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

ធាតុដ៏សំខាន់ខាងលើនេះ ត្រូវបានកំណត់នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា។

ក្នុងការឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងគោលដៅដើម្បីពង្រឹងប្រសិទ្ធភាព គុណភាព តម្លាភាព និងឆ្លើយតប តាមតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ក្នុងការផ្តល់សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋ និងដើម្បីបង្កលក្ខណៈឱ្យកាន់តែមានភាពស្និទ្ធស្នាល ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវការចូលរួមតាមបែបប្រជាធិបតេយ្យនៅមូលដ្ឋាន រាជរដ្ឋាភិបាលបានសម្រេចឱ្យបង្កើតឡើងនូវការិយាល័យច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ។ ដើម្បីធានាប្រសិទ្ធភាពនៃដំណើរការរបស់ការិយាល័យច្រកចេញចូលតែមួយ ក្រុង ស្រុក ខណ្ឌ គោលដៅនីមួយៗ ត្រូវរៀបចំឱ្យមានទម្រង់នៃការពិគ្រោះយោបល់ និងការចូលរួម

នានារបស់ប្រជាពលរដ្ឋ ដូចជា: **វេទិកាប្រជាពលរដ្ឋប្រចាំឆ្នាំ វេទិកាសាធារណៈប្រចាំឆមាស ម៉ោងជួបរវាងប្រជាពលរដ្ឋ និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន** ។ល ។

**សៀវភៅណែនាំស្តីពីនីតិវិធី និងដំណើរការនៃការរៀបចំវេទិកាប្រជាពលរដ្ឋប្រចាំឆ្នាំ** ជាឯកសារសម្រាប់ណែនាំដល់ក្រុមប្រឹក្សា គណៈអភិបាលក្រុង ស្រុក ខណ្ឌ មន្ត្រីរដ្ឋបាលក្រុង ស្រុក ខណ្ឌ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ក្នុងការរៀបចំវេទិកាប្រជាពលរដ្ឋប្រចាំឆ្នាំនេះ ។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មានសង្ឃឹមយ៉ាងមុតមាំថា ក្រុមប្រឹក្សា គណៈអភិបាល មន្ត្រី បុគ្គលិក និងអ្នកពាក់ព័ន្ធនានា នឹងអនុវត្តតាមសៀវភៅណែនាំនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិនា ឆ្នាំ ២០១០

**រដ្ឋលេខាធិការ និងជា**

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.**

សក់ សេដ្ឋា

# វេទិកាប្រជាពលរដ្ឋប្រចាំឆ្នាំ

## ១.សេចក្តីផ្តើម

គម្រោងសាកល្បងនៃការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ ត្រូវបានអនុម័ត និងចូលជាធរមាននៅខែមិថុនា ឆ្នាំ២០០៩ ដោយមានការគាំទ្រមូលនិធិពីធនាគារពិភពលោក និងរាជរដ្ឋាភិបាលកម្ពុជា ដែលមានទឹកប្រាក់សរុបជាង ៤,៧ លានដុល្លារអាមេរិក សម្រាប់រយៈពេលបួន(០៤)ឆ្នាំ ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣។ គម្រោងនេះ មានគោលបំណងសំខាន់ក្នុងការលើកកំពស់គោលការណ៍អភិបាលកិច្ចល្អ តាមរយៈការពង្រីកវិសាលភាពសេវាកម្មដែលផ្តល់ដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឱ្យបានទូលំទូលាយដែលត្រូវផ្តល់ជូនអតិថិជននៅកន្លែងតែមួយ និងបង្វិតរដ្ឋបាលឱ្យនៅកៀកជិតនឹងប្រជាពលរដ្ឋ ដើម្បីបង្កភាពងាយស្រួលក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋឱ្យបានឆាប់រហ័ស ប្រកបដោយប្រសិទ្ធភាព គុណភាព តម្លាភាព ឆ្លើយតបទាន់ពេលវេលាទៅនឹងសេចក្តីត្រូវការចាំបាច់របស់ប្រជាពលរដ្ឋ។

គម្រោងនេះនឹងអនុវត្តនៅក្នុងក្រុង ស្រុក ខណ្ឌចំនួន ២៤ នៃរាជធានី ខេត្តទូទាំងប្រទេស ហើយក្នុងឆ្នាំទីមួយ (២០០៩-២០១០) គម្រោង នឹងអនុវត្តនៅក្នុងក្រុង ស្រុកចំនួន ៩ គឺ *ក្រុងបាត់ដំបង ខេត្តបាត់ដំបង ក្រុងសៀមរាប ខេត្តសៀមរាប ក្រុងសួង ខេត្តកំពង់ចាម ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ក្រុងក្រចេះ ខេត្តក្រចេះ*

*ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ក្រុងតាខ្មៅ ខេត្តកណ្តាល និងស្រុកពាមរក៍ ខេត្តព្រៃវែង ។*

ក្នុងឆ្នាំទី២ (២០១០-២០១១) គម្រោងនឹងអនុវត្តនៅក្នុងក្រុងគោលដៅថ្មី ៨ រួមមាន*ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ក្រុងកំពត ខេត្តកំពត ក្រុងដូនកែវ ខេត្តតាកែវ ក្រុងបាវិត ខេត្តស្វាយរៀង និងក្រុងបានលុង ខេត្តរតនគិរី*។

នៅឆ្នាំទី៣ (២០១១-២០១២) គម្រោងនឹងគ្រោងពង្រីកទៅក្រុង ស្រុក ខណ្ឌ សរុបចំនួន ២០ទៀត ដែលក្នុងនោះមានក្រុង ១០គឺ *ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ក្រុងកែប ខេត្តកែប ក្រុងប៉ៃលិន ខេត្តប៉ៃលិន ក្រុងសំរោង ខេត្តឧត្តរមានជ័យ ក្រុងព្រះវិហារ ខេត្តព្រះវិហារ ក្រុងកំពង់ចាម ខេត្តកំពង់ចាម ក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ ក្រុងស្វាយរៀង ខេត្តស្វាយរៀង និងក្រុងព្រៃវែង ខេត្តព្រៃវែង* និងធ្វើការសាកល្បង នៅ*ស្រុកជនបទ ០១* ព្រមទាំងនៅតាមបណ្តាខណ្ឌទាំង០៩នៃ*រាជធានីភ្នំពេញ*ផងដែរ ។

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពនៃការរៀបចំវេទិកាប្រជាពលរដ្ឋ ជាសកម្មភាពមួយក្នុងចំណោមសកម្មភាពជាច្រើនរបស់គម្រោង ដែលមានគោលបំណងផ្តល់ឱកាសឱ្យប្រជាពលរដ្ឋទាំងអស់ដែលស្ថិត នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុង ស្រុក ខណ្ឌ បញ្ចេញមតិ ផ្តល់យោបល់ និងលើកឡើងនូវបញ្ហាផ្សេងៗ ដែលពាក់ព័ន្ធនឹងការិយាល័យច្រកចេញចូលតែមួយ ដើម្បីធ្វើការដោះស្រាយ ។ ផ្អែកលើផែនការសកម្មភាពរបស់គម្រោងសកម្មភាពនេះ ត្រូវរៀបចំឡើងប្រចាំឆ្នាំ

ដោយអង្គការមិនមែនរដ្ឋាភិបាល (NGO) ក្រោមអធិបតីភាពរបស់អភិបាលក្រុង ស្រុក ខណ្ឌគោលដៅ ។

វេទិកានេះ នឹងមានការអញ្ជើញចូលរួមពីអភិបាលក្រុង ស្រុក ខណ្ឌ គោលដៅដែលត្រូវអនុវត្តគម្រោងផងដែរ ។

## ២.នីតិវិធី និងដំណើរការនៃការរៀបចំ

### ២.១ អ្វីទៅជាវេទិកាប្រជាពលរដ្ឋប្រចាំឆ្នាំ?

វេទិកាប្រជាពលរដ្ឋ ជាការជួបប្រជុំប្រចាំឆ្នាំរវាងប្រជាពលរដ្ឋ ជាមួយរដ្ឋបាល ក្រុង ស្រុក ខណ្ឌគោលដៅ ដើម្បីបង្កើនភាពស្និទ្ធស្នាល លើកកំពស់គុណភាពសេវា និងធ្វើឱ្យប្រសើរឡើងនូវការចូលរួមតាមបែបប្រជាធិបតេយ្យនៅមូលដ្ឋាន ។

### ២.២ គោលបំណង

វេទិកាប្រជាពលរដ្ឋ រៀបចំឡើងក្នុងគោលបំណងដើម្បី ៖

- ផ្តល់ពត៌មានអំពីរដ្ឋបាល ក្រុង ស្រុក ខណ្ឌ អំពីការផ្តល់សេវាជូនប្រជាពលរដ្ឋ តាមរយៈការិយាល័យច្រកចេញចូលតែមួយ អំពីយន្តការនៃការសម្រុះសម្រួលដោះស្រាយពាក្យបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋតាមការិយាល័យប្រជាពលរដ្ឋ ។
- ឆ្លើយតបនឹងដោះស្រាយក្តីកង្វល់ និងសំណូមពររបស់ប្រជាពលរដ្ឋ ។
- ប្រមូលនូវមតិយោបល់ និងអនុសាសន៍របស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ធ្វើជាមូលដ្ឋាននៃការកែលំអរដ្ឋបាល និងការផ្តល់សេវា

ឱ្យកាន់តែមានតម្លាភាព យុត្តិធម៌ និងប្រសិទ្ធភាព ។

- បង្កើនភាពជឿជាក់ និងទំនាក់ទំនងកាន់តែជិតស្និទ្ធរវាងប្រជាពលរដ្ឋ និងរដ្ឋបាល ។

## ២.៣. ប្រធានបទ របៀបវារៈ កាលបរិច្ឆេទ និងទីកន្លែង

⧅ **ប្រធានបទ**

ប្រធានបទនៃវេទិកាប្រជាពលរដ្ឋប្រចាំឆ្នាំ ត្រូវលើកឡើងអំពីបញ្ហាដែលពាក់ព័ន្ធនឹងការផ្តល់**សេវាសាធារណៈ តាមរយៈការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ**។

⧅ **ការកំណត់របៀបវារៈ**

របៀបវារៈត្រូវឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ហើយត្រូវទុកពេលជូនប្រជាពលរដ្ឋចូលរួមសួរ និងបញ្ចេញមតិយោបល់ឱ្យបានច្រើន។

**ខ្លឹមសារនៃរបៀបវារៈ**

១- មតិស្វាគមន៍របស់ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

២- ចំណាប់អារម្មណ៍ និងសេចក្តីរាយការណ៍អំពីលទ្ធផលដែលបានអនុវត្តក្នុងរយៈពេល១ឆ្នាំកន្លងមក និងផែនការនាពេលអនាគតរបស់អភិបាលក្រុង ស្រុក ខណ្ឌ

៣- មតិចូលរួមរបស់ប្រធានការិយាល័យប្រជាពលរដ្ឋ

៤- វេទិកាសំនួរ-ចំលើយ

៥- មតិបូកសរុបរបស់អភិបាល ក្រុង ស្រុក ខណ្ឌ

- **កាលបរិច្ឆេទ:**

នៅសប្តាហ៍ទី ២ ខែធ្នូ នៃឆ្នាំនីមួយៗ អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវកំណត់កាលបរិច្ឆេទនៃការរៀបចំធ្វើវេទិកាប្រជាពលរដ្ឋក្នុងដែនដីរបស់ខ្លួន។

- **ទីកន្លែង:**

ត្រូវរៀបចំនៅទីតាំងដែលមានលក្ខណៈសមស្រប មានបរិយាកាសល្អ និងមានភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការចូលរួម ។

## ២.៤ សមាសភាពចូលរួម

- ប្រជាពលរដ្ឋក្នុងក្រុង ស្រុក ខណ្ឌគោលដៅ អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ពាក់ពន្ធ័ អាជីវករ ពាណិជ្ជករ ព្រះសង្ឃ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ អង្គភាព ស្ថាប័ននានា អ្នកសារព័ត៌មាន ឬអ្នកពាក់ព័ន្ធផ្សេងៗទៀត។
- អភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌគោលដៅ ប្រធានការិយាល័យច្រកចេញចូលតែមួយ ប្រធានការិយាល័យប្រជាពលរដ្ឋ និងមន្ត្រីពាក់ព័ន្ធនៃការិយាល័យច្រកចេញចូលតែមួយ។

**<u>ចំណាំ:</u>** អ្នកចូលរួមត្រូវមានស្ត្រីយ៉ាងតិច ៣០ភាគរយចូលរួម។

## ២.៥ នីតិវិធីនៃការចូលរួម

នីតិវិធី នៃការចូលរួមក្នុងវេទិកាប្រជាពលរដ្ឋ :

- ប្រជាពលរដ្ឋ សហគ្រាស ឬក្រុមហ៊ុន អាជីវករក្នុងស្រុក ត្រូវបានអញ្ជើញចូលរួមក្នុងវេទិកានេះ ដែលត្រូវរៀបចំឡើងជារៀងរាល់ឆ្នាំ

- អ្នកចូលរួមម្នាក់ៗមានសិទ្ធិលើកសំណើបន្ថែមលើរបៀបវារៈ បើមានអ្នកចូលរួមភាគច្រើនយល់ព្រម ប្រធានបទនោះត្រូវតែបានពិភាក្សា
- អ្នកចូលរួមម្នាក់ៗមានសិទ្ធិបញ្ចេញយោបល់នៅក្នុងពេលប្រជុំ (ការចូលរួមមតិយោបល់គួរកំណត់ពេលយ៉ាងយូរ ៥នាទីសំរាប់ម្នាក់ៗ)
- លើកឡើងនូវសំនួរ ដែលពាក់ព័ន្ធនឹងប្រធានបទនៃវេទិកា ជុំវិញការផ្តល់សេវាជូនប្រជាពលរដ្ឋ ជៀសវាងការលើកឡើងនូវសំនួរផ្សេងៗ ដែលពុំមែនជាសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- វាគ្មិនត្រូវឆ្លើយតប ឬដោះស្រាយនូវសំនួរនីមួយៗ របស់ប្រជាពលរដ្ឋ
- មិនត្រូវលើកឡើងនូវបញ្ហាដែលពាក់ព័ន្ធនឹងនយោបាយ ឬគណបក្សនយោបាយឡើយ។

## ២.៦ ឧបករណ៍ សម្ភារ និងឯកសារផ្សព្វផ្សាយ

ដើម្បីឱ្យវេទិកាប្រព្រឹត្តិទៅដោយរលូន អ្នករៀបចំត្រូវត្រៀមនូវឧបករណ៍ សម្ភារ និងឯកសារ ដែលមានជាអាទិ៍ :

- **សម្ភារ:** វេទិកា តុ កៅអី ឧគ្ឃោសនស័ព្ទ ឬឧបករណ៍ សម្ភារផ្សេងៗទៀតតាមការចាំបាច់
- **ឯកសារ:** ឯកសារផ្សព្វផ្សាយ សេចក្តីជូនដំណឹង បដា ខិតប័ណ្ណ ផ្ទាំងរូបភាព ព្រឹត្តិប័ត្រ របាយការណ៍សង្ខេប១ទំព័រ ស្តីពីសមិទ្ធផល របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

## ២.៧ ការត្រៀមលក្ខណៈចែងន្យ

ដើម្បីជៀសវាងនូវភាពអសកម្ម ដែលអាចកើតឡើងជាយថាហេតុ ក្នុងពេលដំណើរការវេទិកា ត្រូវត្រៀមលក្ខណៈជាមុនចំពោះហេតុការណ៍ ដែលអាចកើតមានដូចជា :

- មានការប្រែប្រួលលើពេលវេលាកំណត់ ( ត្រៀមកម្មវិធី ឬការចាក់ភ្លេងកំសាន្តអារម្មណ៍...)
- អ្នកសម្របសម្រួល ឬវាគ្មិន អវត្តមាន ( ត្រៀមបំរុងអ្នកអាច ជំនួសបាន)
- ប្រជាពលរដ្ឋមិនបានចូលរួម ឬចូលរួមតិចតួចពេក ( សហការជាមួយអាជ្ញាធរភូមិ ឃុំ សង្កាត់)
- ប្រជាពលរដ្ឋមិនហ៊ានសួរនាំ ឬមានយោបល់ ( ត្រៀមសំណួរដើម្បីទាក់ទាញ ឬបំផុសគំនិត) ។

## ២.៨ របាយការណ៍

របាយការណ៍វេទិកាប្រជាពលរដ្ឋប្រចាំឆ្នាំ ត្រូវរៀបចំដោយអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះកិច្ចសន្យា ក្នុងការផ្គត់ផ្គង់សេវាជាមួយអភិបាលក្រុង ស្រុក ខណ្ឌ។ របាយការណ៍នេះត្រូវចែកជូនអភិបាលក្រុង ស្រុក ខណ្ឌ សាមុី និងចំលងជូនក្រុមប្រឹក្សា និងក្រុមគាំទ្រថ្នាក់ក្រុង ស្រុក ខណ្ឌ របស់ក្រសួងមហាផ្ទៃ ។ របាយការណ៍ នេះអាចផ្តល់ជូនស្ថាប័ន អង្គភាពពាក់ព័ន្ធ និងតំណាងអ្នកចូលរួម ក្នុងករណីមានការស្នើសុំ ។






រៀបរៀង និងចងក្រងដោយ

ក្រុមគាំទ្រក្រុង ស្រុក ខណ្ឌ ក្រសួងមហាផ្ទៃ



មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់

ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ: ០២៣ ៧២៦ ៨៦១,២២០ ៩៣៥

Email: info@owso.gov.kh, Website:

www.owso.gov.kh



គាំទ្រដោយ

រាជរដ្ឋាភិបាលកម្ពុជា

ធនាគារពិភពលោក